# ២.រឿង ប្រាសាទព្រះធាតុទឹកឆា

ដោយប្រទេសខ្មែរយើង ជាប្រទេសមានអារ្យធម៌បរិបូណ៌, កាលអំពីព្រេងនាយ បានជាមានប្រាសាទបុរាណនៅពាសពេញក្នុងផ្ទៃអាណាចក្រទាំងមូល ។ ក្រៅអំពីខេត្តសៀមរាប ដែលមានបុរាណវត្ថុបែបនេះ ច្រើនជាងគេ, យើងប្រទះឃើញនៅខេត្តដទៃៗ ទៀត ក៏មានច្រើនណាស់ដែរ ដូចជាខេត្តកំពង់ធំ, កំពង់ចាម, បាត់ដំបង, និង តាកែវ ។

ដើម្បីឲ្យបានស្គាល់ទីកន្លែងបុរាណៗ ក្នុងប្រទេសជាតិយើង កាន់តែច្បាស់ឡើង, ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមធ្វើសេចក្ដីរាយការណ៍អំពីប្រាសាទបុរាណមួយឈ្មោះ "វត្តព្រះធាតុទឹកឆា" ស្ថិតក្នុងឃុំចម្ការស្វាយ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ហេតុដែលនាំឲ្យយើងលើកប្រាសាទនេះមកអធិប្បាយ ព្រោះសព្វថ្ងៃឈ្មោះ "ទឹកឆា" បានក្លាយទៅជារមណីយដ្ឋានមួយ សម្រាប់ទេសចរជាតិយើង ធ្វើដំណើរទៅកម្សាន្តនៅពេលបុណ្យទានអ្វីមួយ ដែលបានទំនេរពីការងារមមាញឹក ។ ទេសចរទាំងនេះ មិនត្រឹមតែអ្នកនៅក្នុងខេត្តកំពង់ចាមប៉ុណ្ណោះទេ, អ្នកនៅរាជធានីភ្នំពេញក្ដី នៅខេត្តដទៃទៀតក្ដី តែកាលណាពោលពីដំណើរកម្សាន្តក្នុងខេត្តកំពង់ចាមហើយ គេពុំដែលភ្លេចឈ្មោះ "ទឹកឆា" ទេ ។ តើទីនោះមានអ្វីខ្លះ បានជាលេចឮឈ្មោះខ្លាំងម្ល៉េះ?តាមពិត មិនមានភូមិអ្នកស្រុកផ្សារផ្សេវអ្វីឡើយ, ពីដើមមក មានតែតួប្រាសាទថ្មបាក់បែកស្ទើរតែអស់គ្មានសល់ ស្ថិតនៅជាពីរកន្លែងក្បែរគ្នា ហើយនៅប្របប្រាសាទទាំងពីរនេះ មានជ្រោះប្រឡាយទឹកអំពីបុរាណមក ក៏មានទឹកហូរខួបប្រាំងខួបវស្សា គឺរដូវវស្សាសឹងមានទឹកពេញព្រៀប រដូវប្រាំងនៅសល់ត្រឹមក្បាលជង្គង់ ឬ លើក្បាលជង្គង់បន្តិច ។ ទឹកនេះថ្លាឈ្វេង ហើយហូររ៉ិចៗ មិនចេះឈប់ ជាហេតុនាំឲ្យអ្នកផងទៅងូតលេងលំហែប្រាណយ៉ាងសប្បាយរីករាយ ។ សងខាងប្រឡាយទឹកថ្លាខ្យងនេះ មានរុក្ខាលតាវល្លិ ដុះខ្ពស់ស្រោងស្រឹង ប្រទាក់ប្រទិនគ្នាបែបជាព្រៃល្បាត, តែសព្វថ្ងៃគេបានកាប់រំលីង ឲ្យបានជាវាលមួយកន្លែងយ៉ាងធំ នៅត្រង់ផ្លូវទឹកនេះបែកជាផ្ទារធំល្វល្វាច គឺចំត្រង់តួប្រាង្គថ្មដែលយើងអធិប្បាយខាងលើនេះ ។ មិនតែប៉ុណ្ណោះ រាជការបានកសាងជាទំនប់ទឹកមួយសំខាន់ ដើម្បីយកប្រយោជន៍ អំពីប្រឡាយទឹកបុរាណ នាំយកទឹកទៅចែកឲ្យទៅវាលស្រែយ៉ាងធំទូលាយក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម និង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

អាស្រ័យដោយទីកន្លែងត្រជាក់ត្រជុំ, ដោយផ្ទារទឹក, ដោយម្លប់ឈើត្រឈឹងត្រឈៃ និង ដោយទិដ្ឋភាពស្លុតស្មាញ ព្រៃស្រោង ដុះព័ទ្ធប្រាង្គសិលាបុរាណដូច្នោះហើយ, បានជាទេសចរ នាំគ្នាទៅទស្សនាកម្សាន្ត ក្នុងពេលសម្រាកមួយដងមួយកាល នាំឲ្យលេចឮឈ្មោះទីឋាននេះឡើងយ៉ាងខ្ទរខ្ទារ ។ ម្យ៉ាងទៀត គមនាគមន៍ទៅកាន់ទីកន្លែងនេះក៏ជាការងាយផង ត្បិតរថយន្តតូច-ធំ គ្រប់ម៉ាក គ្រប់ធុន ទៅមកបានទាំងអស់ គឺថាបើគេចង់ទៅកាន់ទីកន្លែងនេះ តោងទៅតាមផ្លូវជាតិលេខ ៧ (ផ្លូវពីភ្នំពេញទៅកំពង់ចាម) ទៅដល់ត្រង់ផ្សារព្រៃទទឹង ដែលជាទីតាំងស្រុកព្រៃឈរ មានផ្លូវបំបែក ចូលតាមផ្លូវខេត្ត ខាងឆ្វេងដៃឆ្ពោះទៅទិសខាងជើង ។ នៅសងខាងផ្លូវខេត្តនេះ មានភូមិអ្នកស្រុកជាប់រហូតមិនស្ងាត់ឡើយ ហើយសុទ្ធជាភូមិស្អាតបាត, ផ្ទះក្បឿងដំបូលក្រហមឆ្អៅ ថ្នល់ក៏ចាក់ថ្មរហូតមិនព្រួយ នឹងភក់ជាប់ផុងឡើយ ។ ចូលពីផ្លូវជាតិប្រមាណជា ១៣

គីឡូម៉ែត្រ ដល់ភូមិក្រូច ឃុំក្រូច ត្រូវបែកចេញពីថ្នល់ខេត្ត ងាកទៅស្តាំដៃ តាមផ្លូវលំ សសៀរបណ្តោយតាមប្រឡាយទឹក (ជាប្រឡាយដែលរាជការទើបតែកែរៀបចំជាថ្មីយ៉ាងស្អាត) ប្រមាណជា ៥ គីឡូម៉ែត្រទៀត ទើបទល់ទៅកន្លែងផ្ការទឹកធំ មានបុរាណវត្ថុ ដែលគេហៅថា "ទឹកឆា" នោះ ។

ពិតមែនហើយ តែយើងស្គាល់សព្វថ្ងៃថា កន្លែងនេះ បានជារមណីយដ្ឋានដ៏សំខាន់ សម្រាប់ទេសចរជាតិ, ប៉ុន្តែប្រវត្តិពង្សាវតារ របស់ទីឋាននេះ បិតនៅក្នុងសភាពងងឹតនៅឡើយ ពុំដឹងថា តើទីនេះ ពីបុរាណជាទីអ្វី ? កើតមាន ពីត្រឹមណាមក ?

ដើម្បីជម្រះមន្ទិលទាំងនេះខ្លះ ក្រុមជំនុំទំនៀមទម្លាប់ បានប្រមែប្រមូលឯកសារ ដែលមានតម្កល់ទុកយូរមកហើយផង ហើយចាត់ឲ្យសមាជិកទៅពិនិត្យសង្កេតដល់ទីកន្លែងផង ក៏រៀបចំធ្វើជាសេចក្តីរាយការណ៍ អំពីទីកន្លែងនេះឡើង ដាក់ចំណងជើងថា "ប្រាសាទព្រះធាតុ ឬ វត្តព្រះធាតុ" តាមឈ្មោះបុរាណនៃប្រាសាទ ដែលហៅថា "គុកព្រះធាតុ ឬ វត្តព្រះធាតុ" នៅត្រង់កន្លែងទឹកឆានេះ ។ ពាក្យ "ទឹកឆា" នេះទៀត ក៏ពុំមែនជាពាក្យទើបតែបង្កើតថ្មីដែរ គឺមានតាំងពីយូរណាស់ហើយ ទើបបានជាមានជាប់ហៅ នៅក្នុងសៀវភៅ "សិលាចារឹកនៅប្រទេសកម្ពុជា" របស់លោក ហ្ស-សឺដែស (Inscription du Cambodge par G. Cœdès) សរសេរកំណត់ឈ្មោះកន្លែងនេះថា "វត្តព្រះធាតុនៅទឹកឆា" (Vat Parh That de Tuk-C'a) ។

ដើម្បីនឹងយកជាសំអាង យើងគោងតែងនិយាយតាមសិលាចារឹកមួយ ដែលអ្នកស្រាវជ្រាវបានរកឃើញ ហើយនាំមកតម្កល់ទុកនៅសារមន្ទីរជាតិ នាក្រុងភ្នំពេញសព្វថ្ងៃ ។ សិលាចារឹកនេះ នៅមានរូបរាងល្អស្អាត អក្សរនៅច្បាស់ ជាបន្ទះក្រាស់ កម្ពស់ ១ ម៉ែត្រ (មិនគិតជើងតម្កល់) ទទឹងមុខ ០ម៥០, ខាងកំពូលលើ មានឆ្លាក់ជារូបព្រះគណេស ។ អក្សរចារឹក មានទាំងសងខាង គឺម្ខាងមាន ២៣ បន្ទាត់ ជាភាសាសំស្រ្កឹត នឹងម្ខាងទៀត មាន ១៦ បន្ទាត់ ជាភាសាខ្មែរ ។ សេចក្តីក្នុងសិលាចារឹកនេះហើយ ជាទ្វារបើកចំហ ឲ្យយើងមើលផ្លូវឃើញនូវប្រវត្តិសាស្រ្តដ៏វែងឆ្ងាយ នៃទីកន្លែងនេះ ។

សិលាចារឹកឲ្យការណ៍ថា ទីកន្លែងនេះកសាងឡើង តាំងពី ៩៤៧ ស័ក (គ.ស.១០២៥) ក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី ១ ។ កាលនោះព្រះរាជា ទ្រង់ទទួលប្រោសព្រះរាជទាន តាមសេចក្តីក្រាបបង្គំទូលស្នើអំពីអ្នកប្រាជ្ញម្នាក់ឈ្មោះ "ជង្ឃាល" ហើយដែលមានសន្មតនាមមួយទៀតថា លក្សិន្ទ្របណ្ឌិត ។ លោក ជង្ឃាល បានរកឃើញទីដីមួយកន្លែងក្នុងតំបន់មួយ ហៅថា សិទ្ធិបុរ (ត្រង់កន្លែងទឹកឆាសព្វថ្ងៃ) មានទំនងស្រឡះស្រឡំល្អ ក៏ទូលស្នើចំពោះព្រះរាជា សុំទីនេះធ្វើជាអារាម សម្រាប់ធ្វើសក្ការបូជាចំពោះសាសនាព្រាហ្មណ៍ ដោយថ្វាយទាំងសេចក្តីព្រាងសព្វគ្រប់ សម្រាប់រៀបចំកន្លែងនេះ ទុកជាស្នាដៃដ៏សំខាន់ផង ។ គ្រានោះព្រះបាទសុរ្យវរ្ម័ន ព្រះអង្គទ្រង់ប្រោសព្រះរាជានុញ្ញាត តាមសេចក្តីសុំ ព្រមទាំងប្រទាន នូវទ្រព្យសម្បត្តិជាច្រើនទៀត ដើម្បីជាមធ្យោបាយ ក្នុងការកសាងនេះផង ។ បណ្ឌិតជង្ឃាល ឬ លក្សិន្ទ្របណ្ឌិត ចាប់ធ្វើកិច្ចការស្ថាបនានេះឡើង តាមកម្លាំងព្រះរាជទ្រព្យ និង តាមប្រាជ្ញារបស់លោកក្នុងការបញ្ចុះបញ្ចូល រកជំនួយអំពីអ្នកស្រុក លុះត្រាតែបានហើយស្រេចសព្វគ្រប់ តាមគម្រោងដែលដាក់ថ្វាយព្រះរាជាទ្រង់ទត ។ គឺនៅក្នុងប្រាសាទធំ មានតម្កល់សិវលិង្គមួយនៅកណ្តាល សន្មតនាមលិង្គនោះថា "ស្រីភទ្រេស្វរៈ" និងទេវរូបពីរអម

សងខាង, មួយមាននាមថា "បរមេស្វរៈ) មួយទៀតថា "សរស្វតិ" ។ ចំពីមុខ, ទិសខាងកើត មានគុហាមួយទៀត ជាទេវស្ថាន មានទំហំតូច ដែលសព្វថ្ងៃយើងឃើញបាក់ធ្លាក់ថ្មគរជាគំនរ កប់ក្នុងព្រៃក្បែរប្រឡាយទឹកជ្រោះ មានតែស៊ុមទ្វារមួយនៅសល់ គ្រាន់ជាការបង្ហាញហេតុ តែប៉ុណ្ណោះ ។ ស្ថាបត្យករ បានចាត់ការជីកស្រះមួយយ៉ាងធំទូលាយ នៅចំហៀងខាងស្តាំនៃប្រាសាទ ឲ្យឈ្មោះថា "លក្ស្មិន្ទ្រដាក" ហើយប្រតិស្ឋានលិង្គមាសមួយ តម្កល់នៅកណ្ដាលស្រះផង ។ ព័ទ្ធជុំវិញនៃទីបរិវេណនេះ មានការរៀបចំបានជាស្រុកភូមិមួយយ៉ាងស្តុកស្តម្ភ ដោយប្រជុំអ្នកស្រុកជិតខាង ឲ្យមករស់នៅជួបជុំកុះកុំគ្នាឡើងក្នុងសម័យនោះ ។ ដូច្នេះបរិយាកាសក្រុងថ្មីនេះឯង ក៏បានជាសភាពអ៊ឹកធឹកឡើង ។

ក្រោយដែលរៀបចំរួចស្រេច លក្ស្មិន្ទ្របណ្ឌិត បាននាំព័ត៌មានចូលក្រាបបង្គំទូលព្រះបាទសុរ្យវរ្ម័នទី ១, ព្រះអង្គក៏ទ្រង់ស្តេចយាងប្រារព្ធពិធីសម្ពោធទីកន្លែងនេះ យ៉ាងមហោឡារិក នៅក្នុងឆ្នាំ ៩៤៧ ស័ក (គ. ស. ១០២៥) ដែលយើងចង្អុលម្តងមកហើយពីខាងលើ ។ ក្នុងព្រះរាជពិធីសម្ពោធនេះ ព្រះរាជាទ្រង់ប្រោសប្រទាននូវធនធាន ជាប្រដាប់ប្រើប្រាស់, ពួកពលព្រះ ២៩ នាក់, ដីស្រែនៅជុំវិញប្រាសាទ និងស្រះទឹកនេះទាំងអស់ ព្រមទាំងទីលានធំៗ សម្រាប់ប្រកបពិធី ឬ ជាគ្រឿងលំអ, ទុកជាទ្រព្យផ្ទាល់នៃគុហានេះផង ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានប្រោសព្រះរាជទាន នាមទីកន្លែងនេះ ថា "លក្ស្មិន្ទ្របថ" ដោយនិយមតាមនាមបណ្ឌិត អ្នកកសាង ។

សេចក្តីហូរហែ ដូចអធិប្បាយមកនេះហើយ ជាប្រវត្តិដើមនៃប្រាសាទ និង ទីកន្លែងទឹកឆា ។

ឥឡូវ យើងអធិប្បាយពីទ្រង់ទ្រាយ ដែលនៅជាតម្រាយ សល់មកដល់សព្វថ្ងៃនេះម្តង ព្រោះសម្រាប់ជួយណែនាំផ្លូវពពួកទេសចរយើងដែលត្រូវការទស្សនាទីកន្លែងនេះផង ។

សព្វថ្ងៃ ស្រះបុរាណ ដែលយើងពោលខាងលើថា ជាស្នាដៃបណ្ឌិតជង្ហាលនោះហើយ ដែលជាផ្ទារទឹកដ៏ធំមួយ នៅចំមុខទំនប់ ដែលក្រសួងកសិកម្ម ទើបនឹងស្ថាបនាឡើង ក្នុងបច្ចុប្បន្ននេះ ។ រីឯប្រឡាយទឹកនេះសោត ហូរធ្លាក់ពីសីសប្រភពនៅទិសខាងជើង ក្នុងខែត្រកំពង់ធំឯណោះ ហើយហូរត្រង់មកត្បូង, លុះមកដល់ចំហៀងប្រាសាទនេះ ក៏ធ្លាក់ទឹកចូលក្នុងរង្វះធំមួយដែលយើងហៅថា "ផ្ទារ" ខាងលើនេះឯង ។ ពីបុរាណមក ទឹកដក់ពេញព្រៀបនៅត្រង់នេះ តែមានកូនជ្រោះតូច ។ បែកមែកធាង នាំបង្ហូរយកទឹកទៅចាក់បញ្ចូលដីស្រែ នាភូមិជិតខាងនេះ មានភូមិក្រូច ក្នុងស្រុកព្រៃឈរនោះជាដើម ។ អាស្រ័យប្រឡាយចាស់ដូច្នេះហើយ បានជារាជការខាងកសិកម្ម ចាត់ចែងក្នុងពេល ៥-៦ ឆ្នាំកន្លងទៅនេះ ធ្វើជាទំនប់មួយ រក្សាទឹកក្នុងផ្ទារនេះ ឲ្យរឹតតែច្រើនឡើង សម្រាប់បន្ថែមកម្លាំង ឲ្យហូរទៅតាមប្រឡាយ ដែលគេជីកធ្វើសំអាតជាថ្មី នាំទឹកទៅចាក់ចែកឲ្យស្រែអ្នកស្រុក បានជាច្រើនពាន់ហិកតារ ក្នុងស្រុកព្រៃឈរ និង ស្រុកបារាយណ៍ ។

ប្រឡាយទឹក ដែលហូរនាំទឹកត្រង់មកពីទិសខាងជើង កាត់មកខាងត្បូង ធ្លាក់ចូលផ្ទារធំរួចហើយ ក៏ឆ្ពោះទៅលិចត្រង់ទៅវិញ, ដូចនេះ ប្រឡាយទឹកត្រង់ទឹកឆា មានសណ្ឋានបីដូចជាកែងជាងឈើ ជាកន្លែងដែលគេងូតទឹកលេងសព្វថ្ងៃ គឺនៅចំត្រង់កែងនោះឯង, បើនរណាចូលចិត្តទឹករាក់ ក៏ងូតក្នុងប្រឡាយចាស់ខាងជើង

ទំនប់ ព្រោះប្រឡាយនេះ បាតក្រោមមានទទឹង ប្រមាណជា ៤ ឬ ៥ ម៉ែត្រដែរ ។ ទឹកថ្លាឈ្វេង មើលឃើញបាតរាបស្មើ ដែលមានកូនថ្មដុំតូចៗ តម្រៀបត្រៀបត្រា គួរឲ្យចង់រើសយកមកមើល ឬ អង្អែលលេង ។ កូនត្រីមួយហ្វូងៗ រត់ច្រាសទឹកហូរ ប្រដេញគ្នា ។ ឯអ្នកដែលចេះហែល ចូលចិត្តហែលលេងក្នុងផ្ទៃទឹកជ្រៅផ្នែកខាងត្បូងតំបន់ ដែលជាផ្ទាំងទឹកធំល្វល្វាច ។ ជុំវិញរង្វះទឹកនេះ មានដើមឈើខ្ពស់ៗ ស្រោងស្រឹង ដុះខ្មាន់ខ្មាប់ នាំឲ្យបានជាជម្រក នៃទេសចរ ដែលទៅលេងកម្សាន្តផង និងជាទីជ្រកនៅនៃសត្វបក្សាបក្សីដែលស្រែកឆ្លើយឆ្លងគ្នា បញ្ចេញសូរចម្លែកៗ រឹតតែបង្កើនដួងចិត្តពួកទេសចរ ឲ្យអណ្ដែតអណ្ដូងថែមឡើងទៀតផង ។

ក្រោយពីងូតទឹកជម្រះកាយហើយ ទេសចរ អាចដើរទៅមើលដំណែលប្រាង្គប្រាសាទបុរាណ ដូចមានប្រវត្តិដែលយើងអធិប្បាយមកខាងលើរួចហើយ ។ ជាដំបូង, គេទៅមើលទេវស្ថានខាងកើតសិន ព្រោះនៅជាប់នឹងប្រឡាយ ត្រង់ទីដែលគេងូតទឹកនេះតែម្ដង ចម្ងាយពីវាលទៅ ប្រមាណជា ៥០ ម៉ែត្រប៉ុណ្ណោះ, គឺដើរតាមផ្លូវជើងទក់ៗ ត្រង់ទៅកើតងាកខាងស្ដាំ មើលក្នុងកន្ទ្រប់ព្រៃ ដែលមានវល្លិដុះពាក់ព័ទ្ធគ្នា ប្រតោងទៅដើមឈើគ្របជិតពីលើ ។ ប្រសិនជារដូវប្រាំងជាការស្រួលងាយ តែបើរដូវវស្សា មានដើមបន្លាស្អិតដុះខ្មាន់ខ្មាប់ នាំឲ្យពិបាករុករុលចូល ទៅណាស់ ។ ទីនោះមានតែគំនរថ្មបាយក្រៀមបួនជ្រុងទ្រវែងៗ ប្រគងប្រគាក់លើគ្នា មានទាំងដីជាប់ជិតពីលើ នាំឲ្យដុះកូនឈើតូចតាច គ្របដណ្ដប់ដំណែលនេះផង គ្រាន់តែមានរាងជាខ្លោងទ្វារមួយ គឺមានថ្មដំវែងៗ បញ្ឈរពីរ និងគងពីលើមួយ សល់ជាដំណែលអាចឲ្យសំគាល់បានថា ជាខ្លោងទ្វារតែប៉ុណ្ណោះ ។

មើលទីនេះរួចហើយ គេថយមកតាមផ្លូវដដែលវិញ, ដើរតាមប្រឡាយទឹកបត់កែងងាកទៅស្ដាំ គឺទៅលិចប្រមាណជា ២០០ ម៉ែត្រ មានស្ពានបេតុង ដែលជាទំនប់ សម្រាប់ទប់កុំឲ្យទឹកហូរខ្លាំងពេក កាលណាបើមានទឹកតិច ហើយមាត់រង្វះនេះ អាចបើកឲ្យហូរខ្លាំងបាន, កាលណាបើមានទឹកច្រើនបរិបូណ៌ គឺថាត្រង់នេះ ជាតំបន់មាត់រង្វះបើក-បិទប្រឡាយទឹក តាមគេត្រូវការ ម្ល៉ោះហើយបានជាពីខាងលើ ត្រូវធ្វើឲ្យមានសណ្ឋានដូចជាស្ពាន ដែលអាចឲ្យគេដើរឆ្លងបាន ។ ឆ្លងពីកូនស្ពាននេះទៅ យើងនឹងប្រទះផ្លូវលំស្រឡះស្រឡំ នៅបណ្ដោយអែបប្រឡាយនេះឯង ។ យើងបែរស្ដាំ ដើរតាមផ្លូវលំនេះ ប្រមាណជា ២០០ ម៉ែត្រទៅទៀត ស្រាប់តែប្រទះនៅខាងឆ្វេងដៃយើង នូវគំនរថ្មបាយក្រៀម ដែលរុះធ្លាក់រប៉ាត់រប៉ាយបង្គរគ្នាខ្លះ នៅជាប់តម្រៀបគ្នាជាកំពែងបន្ទាយខ្លះ ប៉ុន្តែគ្មានក្បាច់រចនាឆើតឆាយទេ ។ មិនតែប៉ុណ្ណោះ មានដើមស្រឡៅ, ដើមឈើទាល, ដើមសំពោង ដុះចាក់ឫសច្រវាត់ច្រវែងដូចពស់លូនប្រពាក់ប្រព័ន្ធគ្នា ពីលើគំនរថ្ម ឬ លើកំពែងថ្មនេះ មានទំហំពីរឱប ឬ បីឱបមនុស្ស ខ្ពស់លលៃ ងើយមើលជ្រុះឈ្នួតពីក្បាល ។ ត្រង់នេះ នាំឲ្យយើងនឹកស្ញើចរន្ធត់ចិត្ត ព្រោះទំហំដើមឈើដ៏ធំមហិមាទាំងនោះ ពុំគួរណាដុះលើគំនរថ្មទាំងនេះកើតសោះ ហើយថ្មនេះទៀត ក៏ពុំគួរណានឹងទ្រទម្ងន់ដើមឈើដ៏សម្បើមៗ ទាំងនេះរួចឡើយ ។ កំពុងតែគិតយ៉ាងនេះ យើងស្រមៃភ្លែត ទៅដល់ប្រាសាទតាព្រហ្មនៅវង់អង្គរ ដែលមានភាពទ្រុឌទ្រោម ហើយមានដើមឈើធំ ដុះគ្របសង្កត់ជាច្រើនកន្លែង ពាសពេញតែបរិវេណប្រាសាទ ដែលមានទំហំធំទូលាយ ជាងគុកព្រះធាតុ ដែលយើងអធិប្បាយនេះទៅទៀត ។

យើងឈានជើងចូលទៅ ក្នុងបរិវេណគុកគុហាបុរាណនេះ យើងប្រទះឃើញរាងវៅជាបួនជ្រុងទ្រវែង បែរមុខឆ្ពោះទៅខាងកើតចំ មានតែទ្វារចូលពីរខាងកើតមក, ឯខាងជើង និង ខាងត្បូង មានតែបង្អួចបីធំវែង ប្រកបដោយចម្រឹងថ្ម ក្រឡឹងជាក្បាច់ជើងទៀន, ចំណែកខាងលិចចំ ពុំមានទ្វារបង្អួចទេ ។ សព្វថ្ងៃ ជញ្ជាំងជុំវិញ នៅគង់ទ្រង់នៅឡើយ ដែលយើងនិយាយមកហើយថា មានដើមឈើធំៗ ដុះពីលើនោះឯង ។ រីឯដំបូល ឬ កំពូលប្រាង្គវិញ គ្មាននៅសល់បន្តិចទេ, សព្វថ្ងៃ នៅតាលហាលរកឲ្យយើងសន្និដ្ឋានថា តើប្រាង្គគុហានេះពីដើមឡើយ មានកំពូលដូច្នេះ ឬ ដូច្នោះពុំបានឡើយ, ឃើញមានតែថ្ម ធ្លាក់មកគរនៅកណ្ដាលបរិវេណ តែមានថ្មខ្លះមានរាងវៅទំនងជាថ្នាក់កំពូល គឺក្បាច់ត្របកឈូក ដែលគេសម្រាប់បន្ទុបធ្វើជាកំពូលប្រាង្គ ធ្លាក់មកគរលាយឡំជាមួយថ្មដទៃទៀតច្រើនផង ។ ទំហំតួប្រាសាទនេះ មានបណ្ដោយប្រមាណ ២០ ម៉ែត្រ ទទឹង ១៥ ម៉ែត្រប៉ុណ្ណោះ ។ ដុំថ្មទាំងនោះ ភាគច្រើនជាថ្មបាយក្រៀម ពុំសូវមានថ្មសំលៀង ដែលឆ្លាក់ជាក្បាច់ក្បូរឆើតឆាយអ្វីឡើយ ប្រទះឃើញតែផ្តែ (Linteau) មួយ ដែលមានឆ្លាក់ជារូបព្រះនារាយណ៍ នៅចំកណ្ដាល និង ក្បាច់ស្លឹកភ្ញីនៅព័ទ្ធព័ន្ធជុំវិញ ។

ការទស្សនាបុរាណដ្ឋាននេះ ធ្វើបានស្រួលតែនៅរដូវប្រាំង ជាជាងរដូវវស្សា ហើយពេលថ្មើរម៉ោនក៏មិនទាស់ ព្រោះមានដើមឈើធំៗ ត្រជាក់ត្រឈៃ មិនព្រួយពីក្ដៅឡើយ, ប៉ុន្តែពេលល្ងាច ឆាប់ងងឹតបន្តិច ដោយសារម្លប់ឈើធំទាំងនោះ ។ ភាគច្រើន អ្នកទស្សនាទីកន្លែងនេះ គេចូលចិត្តទៅនៅពេលព្រឹក ប្រមាណជាម៉ោង ៨-៩ ព្រោះបានឱកាសវែងបន្តិច គឺទៅដល់ហើយ គេទស្សនាពីបុរាណទាំងនេះ ឲ្យសព្វគ្រប់រហូតដល់ម៉ោង ១១-១២ ថ្ងៃត្រង់, បន្ទាប់មក គេរៀបម្ហូបម្ហាអាស្រ័យតាមបែបដើរព្រៃ, អាស្រ័យរួច គេសម្រាកដេកលេងក្រោមដើមឈើដ៏ត្រជាក់ត្រឈៃរហូតម៉ោង ២-៣ ទើបក្រោកឡើង ងូតទឹកលេង លុះដល់ម៉ោង ៤-៥ រសៀល ទើបចេញដំណើរត្រឡប់មកលំនៅវិញ ។ បើជួនជាដំណើរវិលត្រឡប់នេះ ជាពេលរសៀលទាបខ្លាំងបន្តិចផង, សម្រែកបក្សី និង ជំនោរពេលល្ងាច រណ្ដំស្លឹកឈើ ព្រមជាមួយកម្មរស្មីដ៏ស្រទន់នៃព្រះសុរិយាហៀបនឹងអស្ដង្គត ច្បាស់ជារត់មកបបោសអង្អែលដួងចិត្ត នៃទេសចរមិនឲ្យដាច់អាល័យបានឡើយ ហាក់ដូចជាបណ្ដុះសេចក្តីនឹករលឹកមួយ ឲ្យមកលេងទីនេះ នៅពេលណាមួយទៀតជាមិនខាន ។